# ការសម្ភាសរបស់អ៊ុំប្រុស ជា ជួន

**កៈ អ្នកសម្ភាសគេឈ្មោះជាង ស៊ីអ៊ាវ  ខៈ អ្នកអោយគេសម្ភាសមានឈ្មោះ ជា ជួន**

## ការសង្ខេបប្រវត្តិរបស់អ៊ុំប្រុស ជា ជួន

លោកតា សេងច្រឹច មានអាយុ៨៩ ឆ្នាំក្នុងឆ្នាំ២០១៩មានភេទ ប្រុស ទីលំនៅបច្ចុប្បន្ននៅភូមិគោកស្រុក ឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយតាទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសម្ភាសទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYUហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ហ្នឹងបានដឹងពីប្រវត្តិឪពុកម្ដាយហ្នឹងដូនតា ចឹងអ៊ុំយល់ព្រមដើម្បី?

ខៈ ហ្នឹង!

កៈ ដាក់ការសម្ភាសទៅក្នុងវេបសាយសាលាទេអ៊ុំ?

ខៈ បាទ!

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសអ៊ុំខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវហើយថ្ងៃខែដែរខ្ញុំសម្ភាសអ៊ុំគឺនៅថ្ងៃទី៩ ខែ៣ឆ្នាំ២០១៩។

ខៈ បាទ!

កៈ ហើយការសម្ភាសទាំងអស់ហ្នឹងគឺឡើងនៅភូមិគោកស្រុក ឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំចឹងសំរាប់..?

ខៈ បាទខេត្តកំពង់ធំយើង។

កៈ បាទចឹងសំរាប់អ៊ុំគិតថាឈ្មោះអ៊ុំទាំងត្រកូលឈ្មោះអីគេអ៊ុំ?

ខៈ ជា ជួន។

កៈ ជា ជួនចុះមានឈ្មោះហៅក្រៅអត់អ៊ុំ?

ខៈ ថាម៉េច?

កៈ មានឈ្មោះហៅក្រៅអត់អ៊ុំមានមិត្តភក្តិអ៊ុំហៅអ៊ុំអីផ្សេងអីទៀតអត់?

ខៈ ហៅតា?

កៈ បាទ!

ខៈ តាមានហែម។

កៈ អត់ទេប៉ុន្តែចង់និយាយថាអ៊ុំហាស?

ខៈ អ៊ូ!

កៈ មានមិត្តភក្តិហៅឈ្មោះអ៊ុំអីក្រៅពីជា ជួនហ្នឹងអត់?

ខៈ អត់មានទេ។

កៈ ចុះមានតែឈ្មោះមួយហ្នឹងទេអ៊ុំណេះអ៊ុំសព្វថ្ងៃអាយុប៉ុន្មានអ៊ុំ?

ខៈ អាយុសែបួន។

កៈ សែបួនណេះអ៊ុំណេះ?

ខៈ បាទ!

កៈ ចុះអ៊ុំដូចជាអ៊ុំឆ្នាំជូត ឆ្លូវ ខាល ថោះអ៊ុំឆ្នាំអីគេអ៊ុំ?

ខៈ ឆ្នាំរោង។

កៈ ឆ្នាំរោងហោស?

ខ៖ អ៊ុំឆ្នាំម៉្សាញ់។

ក៖ ឆ្នាំម៉្សាញ់អ៊ុំណោះ?

ខ៖ ឆ្នាំម៉្សាញ់។

ក៖ ចុះអ៊ុំគិតថាអ៊ុំស្រុកកំណើតដែរអ៊ុំកើតអ៊ុំកើតនៅណាអ៊ុំ?

ខ៖ កើតនៅគោកស្រុកហ្នឹង!

ក៖ កើតនៅគោកស្រុកហ្នឹងម៉ងហោសអ៊ុំអ៊ុំបាទអ៊ុំ?

ខ៖ កំណើតយើងនៅនេះតើ!

ក៖ បាទអ៊ុំអ៊ុំមានបងប្អូនប៉ុន្មាននាក់អ៊ុំបងប្អូនបង្កើត?

ខ៖ បងប្អូនចាំមើលហាសប្រុសមួយ ពីរ បី បួនប្រុសបួនស្រីមួយ។

ក៖ ចឹងប្រាំ..?

ខ៖ អ៊ុំស្រីពីរ។

ក៖ ចុះប្រាំមួយនាក់ណោះអ៊ុំណោះ?

ខ៖ ប្រុសបួនស្រីពីរ។

ក៖ អ៊ុំអាចប្រាប់ឈ្មោះបងប្អូនអ៊ុំបានទេថាគាត់ឈ្មោះអីគេខ្លះអ៊ុំ?

ខ៖ រ៉ុំ អាសំណាង ហេងសំណាង។

ក៖ បាទអ៊ុំបាទ!

ខ៖ អ៊ុំទៅណោះទៅលោតកៅស៊ូបើនេះវីសំណាង រ៉ុំធីប៉ុនអាខ្មោចងាប់មួយហើយងាប់មួយហ្នឹងអ៊ែន។

ក៖ អ៊ុំបាទអ៊ុំបាទហើយ..?

ខ៖ នៅជា ជូន ណែសំណាង រុំ ហ្នឹងណែប៉ុន្តែខ្មោចមួយងាប់បានហើយ អាយីអាយំ។

ក៖ ស្លាប់ម្នាក់ហោសអ៊ុំ?

ខ៖ ស្លាប់តែអាយីម្នាក់។

ក៖ អូ៎!

ខ៖ ស្លាប់តែម្នាក់។

ក៖ បាទអ៊ុំហើយចុះបងប្អូនអ៊ុំសព្វថ្ងៃគាត់នៅណាទៅអ៊ុំ?

ខ៖ នៅភូមិយើង។

ក៖ នៅភូមិហ្នឹងទេណោះអ៊ុំណោះ?

ខ៖ អាមួយនៅណោះរសេះសំបកហោស!

ក៖ អូ៎!

ខ៖ នៅភូមិថ្មីនេះនៅភូមិទាំងអស់គ្នា។

ក៖ គាត់ធ្វើអីគេអ៊ុំនៅហ្នឹង?

ខ៖ ថាម៉េច?

ក៖ គាត់ធ្វើអីគេនៅហ្នឹង?

ខ៖ ធ្វើចំការធ្វើតែស្រែដូចតែយើងចឹង។

ក៖ អូ៎!

ខ៖ នេះផ្ទះប្អូនខ្ញុំបង្កើត។

ក៖ នេះអ៊ុំហោស?

ខ៖ នោះៗ!

កៈ អ៊ូ!

ខៈ ប្អូនខ្ញុំបង្កើត។

កៈ បាទ!

ខៈ ផ្ទះប្អូននោះ។

កៈ ចុះអ៊ុំគិតថាដូចជាចឹងឪពុកអ៊ុំឈ្មោះអីគេអ៊ុំ?

ខៈ ឈ្មោះជា។

កៈ ត្រកូលគាត់ឈ្មោះអីគេ?

ខៈ ឡុងជា។

កៈ ឡុងជាណោះអ៊ុំណោះ?

ខៈ បាទ!

កៈ ចុះម្ដាយអ៊ុំឈ្មោះអីគេ?

ខៈ ថាម៉េច?

កៈ ម្ដាយអ៊ុំឈ្មោះអីគេអ៊ុំ?

ខៈ យាយអន។

កៈ យាយអនតែត្រកូលគាត់អីគេអ៊ុំត្រកូលគាត់អីគេ?

ខៈ ហែម។

កៈ ហែម អន?

ខៈ បាទ!

កៈ អ៊ូចុះអើដូចជាឪពុកម្ដាយរបស់អ៊ុំគាត់នៅរស់រឺក៏ស្លាប់ហើយ?

ខ៖ ស្លាប់អស់ហើយ!

ក៖ អូ៎ចុះឪពុករបស់អ៊ុំកាលពីមុនគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិត ចិញ្ចឹមកូនចៅអ៊ុំ?

ខ៖ អើគាត់ធ្វើស្រែចម្ការ។

ក៖ ចឹងអ៊ុំហោស?

ខ៖ ហ្នឹង!

ក៖ ហើយចុះម្ដាយអ៊ុំ?

ខ៖ គាត់ធ្វើស្រែដែរ។

ក៖ អូ៎គាត់កាចអត់អ៊ុំ?

ខ៖ គ្មានកាចអីទេគាត់ហោស!

ក៖ គាត់ស្លូតទេហោស?

ខ៖ ហ្នឹងហើយគាត់ចេះកាចអីគាត់។

ក៖ អ៊ុំធ្លាប់មានអនុស្សាវរីយ៍ជាមួយឪពុកម្ដាយកាលអ៊ុំនៅក្មេងជាមួយគាត់អត់?

ខ៖ អើ!

ក៖ ដូចជាអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះជាមួយគាត់ទៅបង់សំណាញ់បង់ត្រី?

ខ៖ កាលមុន..។

ក៖ អូ៎!

ខ៖ ទៅធ្វើស្រែធ្វើចំការធ្វើអីបាទ!

ក៖ អូ៎!

ខ៖ ហ្នឹងធ្វើចម្ការកត្រីរកអី។

កៈ បាទអ៊ុំបាទ!

ខៈ ធ្វើទាហ៊ាន។

កៈ អូ៎ប៉ុន្តែអ៊ុំអាច..?

ខៈ ចូលធ្វើទាហ៊ានមួយសារ។

កៈ បាទអ៊ុំ!

ខៈ ប៉ុនទាហ៊ានយើងហាសទាហ៊ានប៉ុលពតអីសម័យហ្នឹង!

កៈ ចុះ..?

ខៈ ទាហ៊ានខ្មែរ។

កៈ អ៊ុំអាចប្រាប់ពីជំនាន់ប៉ុលពតខ្លះបានទេអ៊ុំធ្លាប់ជួបការលំបាកអីខ្លះអ៊ុំ?

ខៈ អើប៉ុលពតហោស!

កៈ បាទអ៊ុំ!

ខៈ យើងហោសវារែកដីរែកធ្លីប្រើយើងរីហ្វក់ហោស!

កៈ អ៊ុំពេលណុងនៅណាអ៊ុំ?

ខៈ សារអីនៅអូនវែតូចៗចេះតែទៅហោសគេប្រើដូចនៅវត្តយើងរួចមកធ្វើនេះវិញ។

កៈ អូ៎!

ខៈ ហ្នឹងធ្វើពេលប៉ុលពតចូលមកគ្មានធ្វើអីទេ។

កៈ អូ៎!

ខៈ ហ្នឹង!

កៈ គេជំលាសអ៊ុំទៅម្នាក់ឯងក៏តែជំលាសបងប្អូនទាំងក្រុមគ្រួសារ?

ខ៖ អត់ទេគ្នាច្រើនដល់យូរអោយអូនមកត្បាញបង្គីគេអោយធ្វើហាស!

ក៖ បាទអ៊ុំ!

ខ៖ បោចល្អាក់ដូចត្បាញបង្គីហាស!

ក៖ បាទអ៊ុំបាទ!

ខ៖ ត្បាញបង្គីហើយត្បាញ់បង្គីជួយធ្វើបង្គីអង្គុយត្បាញបង្គីអោយទៅវិញបានតែបង្គីទេ។

ក៖ បាទអ៊ុំហើយចុះអ៊ុំពិបាកអត់អ៊ុំពេលណុងអ៊ុំ?

ខ៖ មិនសូវពិបាកទេព្រោះអង្គុយត្បាញបង្គីអោយគេតិចៗ។

ក៖ បាទអ៊ុំបាទហើយចុះអ៊ុំគិតថាអ៊ុំមានជំលាសទៅណាផ្សេងទៀតអត់អ៊ុំ?

ខ៖ អត់ទេ។

ក៖ នៅតើ..?

ខ៖ នៅតែមួយកន្លែង។

ក៖ អូ៎!

ខ៖ មានតែទៅខាងយើងអូរអណ្តែង តាំងក្រសៅហ្នឹងនៅតែនោះផ្ទះនេះឯងវិលៗ។

ក៖ បាទអ៊ុំបាទ!

ខ៖ ហ្នឹងហើយ!

ក៖ ហើយចុះអ៊ុំគិតថាដូចជាបងប្អូនអ៊ុំគេអោយទៅណាអ៊ុំ?

ខ៖ អើបងប្អូនខ្ញុំគេសំលាប់អស់ហើយ!

ក៖ គេសំលាប់អ៊ុំហោស?

ខ៖ ឪពុកក្មេកប៉ុលពតវាសំលាប់។

កៈ អូ៎ហើយចុះអើប៉ុលពតបងប្អូនរបស់អ៊ុំធ្វើអីអ៊ុំ?

ខៈ ធ្វើប្រធានភូមិ។

កៈ ប្រធានភូមិអ៊ុំហោស?

ខៈ បាទ!

កៈ អូ៎!

ខៈ គេសំលាប់ចោលបាទ!

កៈ ចឹងអើរបបអាហារអ៊ុំអីម៉េចដែរអ៊ុំ?

ខៈ ហូបបបរ។

កៈ ហូបតែបបរណោះអ៊ុំណោះ?

ខៈ ហូបបបរហូបបាយធ្វើការធម្មតា។

កៈ អូ៎!

ខៈ មានគេយកទៅវ៉ៃចោល។

កៈ បាទអ៊ុំបាទហើយចុះអ៊ុំគិតថានៅពេលដែរអ៊ុំដាច់ប៉ុលពតមកវិញអ៊ុំមកជួបជុំបងប្អូនអ៊ុំនៅហ្នឹងវិញណោះអ៊ុំណោះ?

ខៈ មកវិញដោយខ្លួនយើងតើ!

កៈ អូ៎ប៉ុន្តែអ៊ុំធ្វើអីទៅជាមួយបងប្អូនអ៊ុំ?

ខៈ មកជួបបងប្អូនវិញអត់ទាន់យកគ្រួសារទេធ្វើទាហ៊ានសិន។

កៈ អ៊ុំធ្វើទាហ៊ានហោស?

ខៈ បាទធ្វើទាហ៊ានធ្វើទ័ព។

កៈ គេចាប់អោយអ៊ុំធ្វើទាហ៊ានរឺក៏អ៊ុំចង់ធ្វើ?

ខៈ អត់ធ្វើទាហ៊ានយើងទាហ៊ានយើងនេះណាគេអត់ចាប់ទេ។

កៈ អូ៎!

ខៈ បាទទាហ៊ានកាន់ទ័ព។

កៈ អូ៎កាលណុងឆ្នាំណាអ៊ុំឆ្នាំប៉ៃត្រជាងមែន?

ខៈ ឆ្នាំប៉ៃត្រចិតប្រាំបួនចិតប្រាំបីយើងប៉ៃត្រ។

កៈ អូ៎!

ខៈ ធ្វើទាហ៊ានពីរឆ្នាំឈប់ហ្នឹង!

កៈ ពេលណុងធ្វើទាហ៊ានម៉េចទៅអ៊ុំពិបាកអត់អ៊ុំ?

ខៈ កាលវ៉ៃខ្មែរហ្នឹងខ្មែរគ្នាឯងហើយប្អូនប្រុសៗតគ្នាប្រលែងគ្នាយូរៗទៅឃើញទាំងអស់គ្នាឈប់រំសាយក៏រំសាយទ័ព។

កៈ ម៉េចចឹងអ៊ុំ?

ខៈ ហ្នឹងឯងបាញ់ៗបាញ់ខ្មែរគ្នាឯងតើដល់យូរៗទៅក៏ជួបគ្នាអូ៎អត់កើតទេអាដែងរំសាយបាញ់ខ្មែរៗគ្នាឯង!

កៈ អូ៎!

ខៈ ដល់ពេលទៅវាឈប់ហ៊ុនសែនទៅចរចារទៅណៃក៏ឈប់ទៅណៃសំរាកទាំងអស់គ្នា។

កៈ បាទអ៊ុំបាទ!

ខៈ ហ្នឹងហើយបាទឈប់បាញ់។

កៈ ហើយចុះអ៊ុំគិតថាអើនៅពេលដែរពេលណាអ៊ុំការមានប្រពន្ធអ៊ុំ?

ខៈ ការអ៊ុំការភ្លេចឆ្នាំបាត់ហើយយូរដែរហើយ!

កៈ នៅឆ្នាំប៉ែត្រជាងរឺក៏កៅជាងអ៊ុំ?

ខៈ ប៉ែត្រពីរប៉ែត្របី។

កៈ អូ៎!

ខៈ ហ្នឹងប៉ែត្របីហោស!

កៈ ដល់ពេលអ៊ុំការអ៊ុំគិតថាមានការលំបាកអីអ៊ុំដោយសារពេលណុងមាន…?

ខៈ អត់អត់មានលំបាកទេពេលការអត់ចង់យកផងយកទៅធ្វើការទាំងអស់ដូចធ្វើការនៅខេត្តចំការនេះនៅនោះ។

កៈ ប៉ុន្តែ..?

ខៈ កាលណុងវា..។

កៈ អ៊ុំមិញអ៊ុំប្រាប់ថាអ៊ុំចេះដូចជាចេះលេងភ្លេងណេះអ៊ុំណេះ?

ខៈ ចេះលេងភ្លេងធ្វើតុធ្វើទូធ្វើនេះធ្វើនោះចេះធ្វើ។

កៈ អ៊ុំចេះមកពីនរណាគេអ៊ុំ។

ខៈ រៀនខ្លួនឯងទៅរៀនឯស្រុកសណ្តាន់ហោស!

កៈ អូ៎!

ខៈ អ៊ុំរៀនស្រុកសណ្តាន់ពីរខែជាង។

កៈ អ៊ុំទៅរៀនហ្នឹងកាលឆ្នាំណាអ៊ុំ?

ខៈ ទៅម៉ាតាំងពីកូនខ្ញុំនៅអាតូចវាគិតខែភ្លេចបាត់ហើយយូរពេក។

កៈ អូ៎!

ខៈ ចាំមើលយូរហោសតាំងពីអាយុពីរបីបួនឆ្នាំ។

កៈ ប៉ុន្តែដាច់ប៉ុលពតហើយណេះអ៊ុំណេះ?

ខៈ ដាច់រួចយូររួចយូរហើយ!

កៈ អ៊ុំនឹកឃើញម៉េចអ៊ុំចាប់អារម្មណ៍ខាងរៀនភ្លេងអ៊ុំ?

ខៈ រៀនមុនដំបូងលេងលេងពីរបីឆ្នាំលេងរហូតដល់កំពង់ធំ។

កៈ បាទ!

ខៈ លេងទៅបង្ហាត់រៀនលេងយូរៗឈប់ទៅធ្វើការអីនោះទៀតបកពីវាងាប់ណៃដៃគូរ។

កៈ អូ៎!

ខៈ អត់មានអ្នកលេងឈប់ផ្អាក។

កៈ អស់គ្នាលេងជាមួយអ៊ុំហោស?

ខៈ បាទហ្នឹងហើយ!

កៈ ប៉ុន្តែ..?

ខៈ វានៅផ្ទះហ្នឹងឯង!

កៈ ប៉ុន្តែអ៊ុំលេងលេងអីគេខ្លះដែរអ៊ុំ?

ខៈ ភ្លេងការក៏ត្រូវភ្លេងអីក៏ត្រូវដែរ។

កៈ អ៊ុំលេងទាំងអស់ណោះអ៊ុំ?

ខៈ លេងភ្លេងអារក្សអីលេងហាស!

កៈ បាទអ៊ុំ!

ខៈ លេងភ្លេងការក៏លេងបានទាំងអស់។

កៈ អូ៎!

ខ៖ គ្រប់មួយគ្រឿង។

ក៖ ថាអីក៏អ៊ុំលេងដែរណោះអ៊ុំណោះ?

ខ៖ បាទចំរៀងអីបទអីក៏បានដែរ។

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ ចំរៀងបាទចេះ។

ក៖ ហើយចុះអ៊ុំគិតថាអើពេលដែរយើងមានកូនយើងអត់មានមានការលំបាកអត់អ៊ុំ?

ខ៖ អត់ទេអត់មាន។

ក៖ ជីវភាពយើងធូរធារទេណោះអ៊ុំ?

ខ៖ ធូរធារប៉ុនអ៊ុំឈឺម្ដងៗ។

ក៖ អូ៎!

ខ៖ ទៅលេងហ្នឹងគេទៅគេដឹងម៉េចដែរគេធ្វើបាបទៅលេងគេនៅលើហោស!

ក៖ បាទអ៊ុំ!

ខ៖ ឈឺមួយខែទៅពេទ្យ។

ក៖ អូ៎!

ខ៖ ហ្នឹងហើយត្រលប់មកវិញដេកទៅពិបាកមួយពេល។

ក៖ បាទអ៊ុំបាទ!

ខ៖ ពិបាកមួយពេល។

ក៖ ហើយចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជីវភាពអ៊ុំធូរធារហើយសប្បាយជាមួយប្រពន្ធកូនអ៊ុំហោសពេលណាអ៊ុំ?

ខ៖ អើសព្វថ្ងៃមានអីយើងគ្រប់គ្រងទៅមើលចៅទៅប្រពន្ធមើលកូនហាស!

ក៖ បាទអ៊ុំ!

ខ៖ ដាំដំណាំចាក់ទឹកចាក់ភក់ទៅអើរកត្រីរកសាច់ធម្មតាទៅពេលយើងកំពង់ទៅលេងភ្លេង។

ក៖ បាទអ៊ុំបាទ!

ខ៖ ហ្នឹងហើយមានការងារប៉ុណ្ណឹង។

ក៖ អ្ហ៎ប៉ុន្តែអ៊ុំទៅរកត្រីរកអីដែរណោះអ៊ុំ?

ខ៖ ទៅរក។

ក៖ ភាគច្រើនអ៊ុំទៅរកត្រីទៅរកត្រីអីគេអ៊ុំ?

ខ៖ ទៅបានត្រីយើងធម្មតាដែរដាក់ម៉ងត្រីគ្រស់ត្រីក្រាញ់ កំភ្លៀនអីទៅដាក់។

ក៖ បានរាល់ថ្ងៃអ៊ុំហោស?

ខ៖ បានកាលណាមួយគឺឡូកន្លះគឺឡូ។

ក៖ តែបានចេះតែបានរាល់ថ្ងៃហាសណោះ?

ខ៖ បាន។

ក៖ អ៊ុំទៅដាក់រាល់ថ្ងៃណោះ?

ខ៖ ហ្នឹងហើយដាក់ទូក។

ក៖ មួយថ្ងៃអ៊ុំទៅដាក់ប៉ុន្មានម៉ោងទៅអ៊ុំ?

ខ៖ ដាក់អើដាក់ប៉ុន្មានមួយម៉ោងទៅ។

ក៖ រួចទៅក៏មកវិញទៅ។

ខ៖ រួចក៏ប្រញាប់ទៅលេងភ្លេងទៅក៏ទុកសិនហើយនេះអោយគេមើលផ្ញើរមកហើយ!

ក៖ ដល់ពេលហើយមកវិញបាន?

ខ៖ ហ្នឹងហើយគេចែកមើលអោយបងប្អូនមើលហាស!

ក៖ បាទ!

ខ៖ ថាផ្ញើរផងទៅលេងភ្លេងវាយប់បានមកវិញ។

ក៖ បាទអ៊ំ!

ខ៖ បានយើង..។

ក៖ បាទហើយចុះអ៊ុំគិតថាដូចជាចឹងពេលហ្នឹងដែរអ៊ុំចាប់ផ្តើមសប្បាយរៀធូរធារហើយ ដោយសារតែកូនបានទៅថៃទៅអីណេះអ៊ុំណេះ?

ខ៖ អើប៉ុន្តែអ៊ុំអាកូនស្រីទៅប៉ុនអ៊ុំរកដែររកចែកផ្លូវប៉ុនថាលែងប្តី។

ក៖ ម៉េចទៅអ៊ុំអ៊ុំនៅតែរកណុងទៀតអត់មានសល់ទេណេះ?

ខ៖ បាទវាមិនបានច្រើនទេបានយើងលេងតែមួយវង្ស។

ក៖ បាន..?

ខ៖ ម្ភៃម៉ឺនប្រាំណែលេង។

ក៖ អ្ហូ!

ខ៖ គិតថាម៉ោងគិតថាម៉ោង។

ក៖ ហើយចុះអើប្រពន្ធអ៊ុំគាត់ធ្វើអី?

ខ៖ ធ្វើនុំលក់ទៅដូរកំប៉េកកំប៉ុកដូចយើងណា។

ក៖ អ្ហូ!

ខ៖ តិចៗផ្សំគ្នាទៅ។

កៈ បាទអ៊ុំបាទ!

ខៈ ដើម្បីរកស៊ីយើងផ្សំគ្នាបានយើងល្អ។

កៈ បាទអ៊ុំបាទបានកូនផ្ញើរលុយទៀតសល់ហាសណោះអ៊ុំ?

ខៈ សល់ហើយ!

កៈ ហើយហ្នឹងបានថៅមួយ?

ខៈ ហើយហ្នឹងថៅ។

កៈ ចុះអ៊ុំទើបមានថៅមួយហ្នឹងទេណោះអ៊ុំណោះ?

ខៈ អើ!

កៈ អ៊ូបាទអ៊ុំបាទហើយចុះអ៊ុំកាលពីក្មេងអ៊ុំធ្លាប់មានគិតគោលបំណងថាអ៊ុំធំឡើងអ៊ុំចង់ធ្វើអីទេអ៊ុំ?

ខៈ តាំងពីក្មេងនៅផ្ទះទេនៅក្មេងដើរចងសន្ទូច។

កៈ ដើរចងសន្ទូច?

ខៈ ចងសន្ទូចរកត្រីតេកតាក់ៗ។

កៈ កាលនៅភូមិហ្នឹងអ៊ុំណោះ?

ខៈ នៅហ្នឹងនៅនេះទៅ។

កៈ ចឹងមានន័យថាអ៊ុំចេះរកត្រីតាំងពីប៉ុណ្ណា?

ខៈ អើរកតាំងពីអាយុបួនប្រាំឆ្នាំហោសប្រាំមួយប្រាំពីរឆ្នាំ។

កៈ អ៊ូ!

ខៈ ផ្ទះកាលណោះហោសនៅណោះ។

កៈ បាទអ៊ុំអ៊ូ៎ហើយចុះអ៊ុំគិតថាចឹងបងប្អូនអ៊ុំទាំងខាងប្រពន្ធអ៊ុំមានតែអ៊ុំមួយដែរចេះលេងភ្លេងណោះអ៊ុំណោះ?

ខៈ ពីរនាក់។

កៈ ពីរនាក់ពីណាអ៊ុំ?

ខៈ នេះប្អូនជា។

កៈ ប្អូនអ៊ុំហោស?

ខៈ ពីរនាក់។

កៈ ប្អូនថ្លៃរឺក៏ប្អូនបង្កើត?

ខៈ ប្អូនបង្កើតហាស!

កៈ អ៊ូ៎!

ខៈ ប៉ុនទៅការបារាយណ៍បាត់ហើយមិនទាន់មកផង។

កៈ អ៊ូ៎!

ខៈ នោះទៅការនៅណោះ។

កៈ ទៅការនៅបារាយណ៍ហោសអ៊ូ៎បាទហើយចុះអ៊ុំគិតថាដូចជាផ្ទះរបស់អ៊ុំកាលពីមុនផ្ទះម៉េចអ៊ុំនៅជាមួយឪពុកម្ដាយហាស?

ខៈ ផ្ទះមុននៅកើតហោសពីរខ្ទងអោយប្អូននៅណោះអ៊ុំនៅណោះ។

កៈ អ៊ុំសុខចិត្តនៅម្នាក់ឯង?

ខៈ អ៊ុំនៅណោះ។

កៈ បាទអ៊ុំបាទហើយចុះអ៊ុំនៅហ្នឹងនៅជាមួយគ្រួសារកូនចៅណោះ?

ខៈ គ្រួសារដីកេរ្ដ៏។

ក៖ កេរ្តិ៍?

ខ៖ កេរ្តិ៍ពូ។

ក៖ អូ៎!

ខ៖ ដីពូទាំងអស់។

ក៖ អូ៎បាទពូបាទហើយចុះពូគិតថាដូចជាសព្វថ្ងៃពូនៅជាមួយប្រពន្ធជីវភាពពូសមញ្ញធម្មតាទេ ណេះពូណេះ?

ខ៖ សមញ្ញយើងរកហូបធម្មតា។

ក៖ អូ៎!

ខ៖ បាទធ្វើការយើងធ្វើទៅគេធ្វើអីធ្វើចុះយើងធ្វើអីធ្វើចុះ។

ក៖ បាទពូ!

ខ៖ ហ្នឹង!

ក៖ ចុះពូគិតថាអើជំនាញអីដែរពូចេះស្ទាត់ជំនាញពូ?

ខ៖ ជំនាញណែផ្ទះក៏ចេះធ្វើនេះគ្រែនេះផ្ទះនេះអ៊ុំធ្វើដែរតើ!

ក៖ អូ៎ពូអ្នកធ្វើផ្ទះហ្នឹងហោស?

ខ៖ បាទធ្វើខ្ញុំធ្វើណោះនោះអាណោះក៏អ៊ុំធ្វើដែរខាងលិចអាខ្ពស់នោះ។

ក៖ បាទពូបាទ!

ខ៖ បាទអ៊ុំធ្វើ។

ក៖ ចឹងមានន័យថាពូចេះធ្វើផ្ទះ?

ខ៖ បាទ!

កៈ គ្រែតុទូ?

ខៈ ចេះអើ!

កៈ អ៊ូ!

ខៈ ប៉ុនមិនទំនេរទេដៃហាស!

កៈ អ៊ូពូ!

ខៈ ហ្នឹងហើយបើថាផឹកត្នោតជូរអីហាសលេងសើចហ្នឹងគេទេប្រាជច្រៀងលេងអីហាស!

កៈ បាទពូ!

ខៈ ទំនេរអង្គុយហាសហ្នឹងឯងសប្បាយចេះសប្បាយ។

កៈ បាទពូបាទ!

ខៈ បើស្រវឹងខ្លាំងដេកហែងផ្លឹង។

កៈ អ៊ូបាទពូហើយ..?

ខៈ អត់ចេះឯង!

កៈ ហើយពូចេះជំនាញធ្វើតុធ្វើទូ?

ខៈ ហ្នឹងឯង!

កៈ ធ្វើផ្ទះហ្នឹងមកពីនរណាគេពូ?

ខៈ រៀនធ្វើខ្លួនឯង។

កៈ ឪពុកពូចេះអត់?

ខៈ ហ្នឹងឯងចំណាំខ្លួនឯង!

កៈ ប៉ុន្តែឪពុកពូចេះអត់?

ខ៖ ចេះទាំងអស់។

ក៖ អ៊ំគាត់ចេះដែរហោស?

ខ៖ ហ្នឹងហើយ!

ក៖ ចឹងពូចេះតពីគាត់ហោស?

ខ៖ តរៀនទាំងអស់គ្នាអាមុនប្អូនមីប្អូននោះនោះអាខ្ពស់នោះផ្ទះបីខ្នងនោះ។

ក៖ បាទពូបាទ!

ខ៖ ណែរួចនោះអានោះៗអើអានោះអីកើតណោះ។

ក៖ ចឹងសុទ្ធតែពូធ្វើ?

ខ៖ បាទ!

ក៖ អ៊ំចឹងពូជាមេជាងពូណោះ?

ខ៖ មេជាងអោយមេជាងពីរនាក់ចេះដូចគ្នាធ្វើ។

ក៖ អ៊ំ!

ខ៖ វាចែកវាអីនេះ។

ក៖ ចឹងភាគច្រើនធ្វើផ្ទះអោយគេមួយបានប៉ុន្មានទៅពូ?

ខ៖ បានប៉ុន្មានទេអោយជួលកូនជាងពីរម៉ឺនបួនពាន់សព្វថ្ងៃយកថ្លៃហាសវាយកថ្លៃវាមុនយកតែមួយថ្ងៃពីរម៉ឺនសព្វថ្ងៃវាយកពីរម៉ឺនបួនអោយវា។

ក៖ ប៉ុន្តែភាគច្រើនផ្ទះមួយធ្វើប៉ុន្មានថ្ងៃទៅពូ?

ខ៖ មួយខែពីរខែណោះពីរខែបានរួច។

ក៖ អ៊ំធ្វើយូរដែរហោសពូ?

ខ៖ ធ្វើពីរខែហោសបានរួចប្រព្រំវ៉ែជញ្ជាំងអោយលេងដែរ។

ក៖ អូ៎បាទពូ!

ខ៖ វ៉ែលេងៗដែរ។

ក៖ អូ៎ចុះពូគិតថាដូចជាកូនៗពូទៅថៃអស់ហើយណោះពូណោះ?

ខ៖ នៅពីរនាក់កូនតែពីរទេ។

ក៖ តែទៅថៃអស់ហើយណោះពូណោះ?

ខ៖ ហ្នឹងហើយ!

ក៖ ទុកចៅមួយអោយពូមើល?

ខ៖ ហ្នឹងឯង!

ក៖ ប៉ុន្តែ..?

ខ៖ តែប្រដាលទៅ។

ក៖ ចុះកូន..?

ខ៖ សួរគាត់សួរ។

ក៖ ពូធ្លាប់បង្រៀនពីជំនាញអីដែរពូចេះទៅកូនចៅពូអត់ពូ?

ខ៖ ចេះអក្សរចេះ។

ក៖ ប៉ុន្តែពូធ្លាប់បង្រៀនទៅកូនពូអត់?

ខ៖ ចេះតើបង្ហាត់។

ក៖ បង្រៀនដូចជាធ្វើផ្ទះ?

ខ៖ បាទ!

កៈ តុទូអី?

ខៈ ហ្នឹងឯងបង្ហាត់បង្ហាត់កៅអីបង្ហាត់កៅអីនៅមើលវាចេះហោស!

កៈ អ៎ូហើយ..?

ខៈ បង្ហាត់ទាំងអស់ហ្នឹងឯង!

កៈ ចឹងហោសពូ?

ខៈ ដោះភ្លើងក៏ចេះភ្លើងក៏ចេះដោះដែរ។

កៈ បាទពូបាទហើយចុះពូពីមុនពូធ្លាប់រៀនអត់ពូ?

ខៈ រៀន។

កៈ ពូរៀនបានថ្នាក់ទីប៉ុន្មានទៅពូ?

ខៈ ថ្នាក់ទីប្រាំបី។

កៈ ថ្នាក់ទីប្រាំបីហោសពូអ៎ូហើយចុះអើកាលពូរៀនរៀននៅណាពូ?

ខៈ រៀនសាលាភូមិយើង។

កៈ អ៎ូដូចជាឆ្កែកាច?

ខៈ ឆ្កែឆ្កែផ្ទះនេះរៀនថ្នាក់ទីប្រាំបីហាសកុំវ៉ៃវាចៅ។

កៈ កាលពូរៀនរៀននៅណាពូ?

ខៈ រៀនភូមិយើង។

កៈ អ៎ូភូមិហ្នឹងហោស?

ខៈ រៀនភូមិយើង។

កៈ អ៎ូហើយកាលពូរៀនហ្នឹងពិបាកអត់ពូឆ្នាំណាទៅពូរៀន?

ខ៖ រៀនតាំងពីយើងដាច់ប៉ុលពតមក។

ក៖ អ៊ូ!

ខ៖ ចាប់ផ្តើមរៀនម៉ង។

ក៖ បាទពូបាទ!

ខ៖ បាទ!

ក៖ ហើយមានការលំបាកអីដែរពូរៀនអត់ពូក្នុងការលំបាកដែរពូរៀនហាស?

ខ៖ រៀននេះធម្មតា។

ក៖ អត់មានពិបាកអីទេណោះពូ?

ខ៖ មានពិបាកអី។

ក៖ អ៊ូចុះពូចាប់ផ្តើមរកស៊ីនៅអាយុប៉ុន្មានពូចេញធ្វើការរកស៊ីហាសណាស់?

ខ៖ បាទរៀនរៀនចប់រៀនថ្នាក់ទីប្រាំបីរួចបានចេញ។

ក៖ ពូកាលណុងពូទៅរកធ្វើការងារហាសណោះពូ?

ខ៖ ហ្នឹងឯង!

ក៖ ទៅ..?

ខ៖ ត្រង់អត់ចង់ឈប់ទេដោយសារប៉ុននេះឯងរៀនទៅគេអត់ចង់អោយឈប់ផងដោយសារពូរៀនទៅអស់លុយច្រើនហាសគិតតែពីចាយ។

ក៖ អ៊ូ!

ខ៖ ចប់ថ្នាក់ទីប្រាំបីចេញទៅរកលុយសិន។

ក៖ បាទពូបាទ!

ខ៖ ហ្នឹងឯងចេញទៅរកលុយមិនកើតទេរៀនបានថ្នាក់ទីប្រាំបីបានហើយបង្ហាត់អាដែងបានហើយ!

ក៖ បាទ!

ខ៖ បងបង្ហាត់គេបានហើយ!

ក៖ បាទពូបាទ!

ខ៖ ហ្នឹងហើយ!

ក៖ ហើយចុះពូចឹងកាលពូរៀនហ្នឹងពូធ្លាប់មានមិត្តភក្តិដែរស្និទ្ធស្នាលធំធាត់មកជាមួយគ្នាអត់ពូ?

ខ៖ មិត្តភក្តិ។

ក៖ មានច្រើនអត់ពូ?

ខ៖ មានច្រើនហាសគ្រូអាហានធ្វើគ្រូនៅភ្នំពេញ អាហាននៅភ្នំពេញ។

ក៖ បាទពូបាទ!

ខ៖ អើបង។

ក៖ ចុះមាននរណាគេ?

ខ៖ អើ..!

ក៖ នៅហ្នឹងអត់ពូមិត្តភក្តិពូហាសមានអត់?

ខ៖ នៅណា?

ក៖ នៅហ្នឹងហាសមានមិត្តភក្តិពូអត់ដែររៀននៅនេះហាស?

ខ៖ នៅភូមិយើងហោស?

ក៖ បាទ!

ខ៖ អើកគោកមិត្តភក្តិ។

ក៖ សុទ្ធមិត្តភក្តិពូ?

ខ៖ ហ្នឹងឯងខ្ញុំដើររហូតធ្វើការណោះណោះនៅតែពីរនាក់។

ក៖ អូ៎!

ខ៖ នេះអាឡានេះធ្វើមេឃុំ។

ក៖ បាទពូបាទ!

ខ៖ បាទ!

ក៖ ហើយចុះពូគិតថាអើកាលពីពូរៀនហ្នឹងពូធ្លាប់មានអនុស្សាវរីយ៍ជាមួយមិត្តភក្តិពូអត់ពូ?

ខ៖ វាមាន។

ក៖ ធ្លាប់ដើរលេងជាមួយគ្នាចាប់ត្រីចាប់ក្តាមទៅលេងទឹកលេងអីជាមួយគ្នាហាសណោះ?

ខ៖ ខ្ញុំមួយសារនេះពុងរៀនចឹងឯងរៀនផងរៀនភ្លេងផង។

ក៖ អូ៎បាទពូ!

ខ៖ អើរៀនភ្លេងពិបាកហ្នឹងកូដទ្រហ្នឹងហើយរៀនទៅឡើងត្នោតទៀតកាលណុង។

ក៖ ពូឡើងត្នោតទៀតហោស?

ខ៖ ឡើងត្នោតទៀត។

ក៖ ចឹងមានន័យថាពូចេះឡើងត្នោតដែរ?

ខ៖ ចេះ។

ក៖ ពូចេះឡើងត្នោតពីនរណាគេឪពុកពូបង្រៀនអោយឡើងមែន?

ខ៖ ឪពុកគាត់ធ្លាប់ឡើងពូខ្ញុំតាហែម។

កៈ បាទពូចុះ..?

ខៈ តាហែមហាសដីគាត់ប៉ុននេះកន្លែងនេះគាត់ជួលគាត់ទាំងអស់សុទ្ធតែដីគាត់នេះ។

កៈ បាទពូបាទ!

ខៈ ដីពូទេទាំងអស់ហ្នឹង!

កៈ បាទពូ!

ខៈ ហ្នឹងហើយហ្នឹងឯងគាត់អ្នកឡើងបាទមួយសារនេះដើរតាមតែគាត់ទេ។

កៈ ឡើងត្នោតពិបាកអត់ពូ?

ខៈ ហ្នឹង!

កៈ ឡើងត្នោតពិបាកអត់ពូ?

ខៈ ពិបាកប៉ុន្តែឡើងធ្វើអាជូរលក់វិញបានលុយដែរ។

ក អូ៎!

ខៈ បានមួយអង្កាញ់ទៅមួយអង្កាញ់ប្រាំពាន់មួយសារនេះ។

កៈ បាទពូបាទ!

ខៈ ប៉ុនសព្វថ្ងៃឈប់ឡើងហើយ!

កៈ អូ៎!

ខៈ រវល់លេងភ្លេង។

កៈ ចឹងពូសព្វថ្ងៃពូធ្វើអី?

ខៈ លេងភ្លេងហើយរកត្រី។

កៈ លេភ្លេងរកត្រី?

ខ៖ បាទ!

ក៖ អ៎បាទពូបាទចុះការស្រែពូធ្លាប់ធ្វើអត់ពូ?

ខ៖ ធ្វើតើស្រែយើង។

ក៖ ធ្វើណោះពូណោះ?

ខ៖ នៅកើតធ្វើតើស្រែ។

ក៖ អ៎ូពូធ្វើស្រែប្រាំងស្រែវស្សាពូ?

ខ៖ អត់ទេធ្វើស្រែវស្សា។

ក៖ ធ្វើតែវស្សាទេណោះពូ?

ខ៖ ឈប់ធ្វើប្រាំងហើយ!

ក៖ ពិបាកមែនពូ?

ខ៖ ពិបាកណាស់។

ក៖ ចុះ..?

ខ៖ មែនថាប្រាំងណា។

ក៖ អ៎ូ!

ខ៖ ធ្វើតែវស្សា។

ក៖ អ៎ូបាទពូបាទ!

ខ៖ បាទ!

ក៖ ហើយចុះពូគិតថាដូចជាពូតាំងពីក្មេងរហូតដល់ឥឡូវការងារអីគេខ្លះដែរពូធ្លាប់ធ្វើពូ?

ខ៖ មានតែរៀនមានធ្វើអីហ្នឹងឯងរកត្រីហ្នឹងឯងលេងភ្លេងហ្នឹងឯង!

កៈ អ៊ូចុះពូគិតថាអើ..?

ខៈ ស្ងួចត្រី។

កៈ អ៊ូចុះពូគិតថា..?

ខៈ ហ្នឹងឯង!

កៈ ពូធ្លាប់លក់ដូរវីមួយក៏ចិញ្ចឹមសត្វអីពីមុនទេពូ?

ខៈ អ៊ូចិញ្ចឹមតើលក់មាន់។

កៈ លក់មាន់លក់អីហោសពូ?

ខៈ ហ្នឹងឯងចិញ្ចឹម។

កៈ ពូចិញ្ចឹមច្រនហោសពូមាន់?

ខៈ ចិញ្ចឹមដប់បួនដប់ប្រាំ។

កៈ អ៊ូ!

ខៈ អើមកទៀតហើយ!

កៈ ចឹងពូចិញ្ចឹមច្រើនដែរហោសពូហោស?

ខៈ អើមាន់បួនប្រាំ។

កៈ អីគេអាហ្នឹង?

ខៈ វាយកអីមកអោយ។

កៈ អ៊ូប្រយ័ត្នមុតដៃអើហើយចុះពូគិតថាអើសំរាប់ដូចជាជីវិតរបស់ពូមានការផ្លាស់ប្ដូរអីខ្លះទៅពូតាំងពីក្មេងរហូតមកដល់ឥឡូវហោស?

ខៈ អើពូគ្មានធ្វើអីទេការងារធ្វើចង់បានតែធ្វើអីប្តូរគ្នាធ្វើ។

កៈ អ៎ូ!

ខៈ ធ្វើនេះធ្វើនោះអោយគេដល់គេជួលហាស!

កៈ បាទពូ!

ខៈ ហ្នឹងឯងដល់គេមកជួលធ្វើតុធ្វើទូទ្រុងមាន់ទ្រុងទាទៅធ្វើអោយគេធ្វើអោយគេទៅហ្នឹងធ្វើអោយគេ។

កៈ អ៎ូបាទពូបាទ!

ខៈ បាទ!

កៈ ហើយចុះពូគិតថាដូចជាម្ហូបអីដែរពូចូលចិត្តហូបពូ?

ខៈ ខ្ញុំហោសដូចថាត្រីអាំងទៅ ចៀនទៅហ្នឹងមីទៅហូបចង់ហូបអីហូបអានេះ។

កៈ អ៎ូ!

ខៈ ហ្នឹង!

កៈ តាមអ្វីដែរយើងនឹកឃើញហោស?

ខៈ នឹកឃើញ។

កៈ អ៎ូចុះពូចូលចិត្តច្រៀងណេះពូណេះ?

ខៈ អ៎ូទៅប្រលងមិនឈ្នះទេ។

កៈ ចឹងមានន័យថាពូពូកែច្រៀងណេះពូ?

ខៈ ប្រលងមិនឈ្នះប្រលងមិនឈ្នះពូទេ។

កៈ អ៎ូ!

ខៈ ទៅប្រលងហើយ!

កៈ ចឹងមានន័យថាពូ..?

ខៈ ចង់បទអី។

កៈ ពូអើ..?

ខៈ ហ្នឹងឯង!

កៈ ពូចូលចិត្តច្រៀងផងហើយពូលេងភ្លេងបណ្តើរច្រៀងបណ្តើរ?

ខៈ ទ្រសោមកាលទៅទ្រទៅហ្នឹងឯងចេះគ្រប់។

កៈ អ៊ំពូ..?

ខៈ ចំរៀងទៅដាក់នេះ។

កៈ ពូចូលចិត្តរាំអត់ពូ?

ខៈ អារាំក៏ត្រូវអោយតែរាំរាំឥឡូវជួលអោយរាំៗពីរៗបទហ្នឹងគេទៅឯង!

កៈ ពូចេះទាំងអស់ចឹង?

ខៈ ហ្នឹងឯងចង់សប្បាយហាស!

កៈ បាទពូបាទ!

ខៈ រាំពីរបីបទទៅរួចលេងទៅអើសម្លាសអី។

កៈ ហើយ..?

ខៈ រាំទៅលេងទៅ។

កៈ ហើយចុះពូគិតថាដូចជាល្បែងប្រជាប្រិយ៍អីដែរពូចូលចិត្តលេង?

ខៈ រាល់ថ្ងៃជក់បារីអីដើម្បីហ្នឹងឯង!

កៈ បោះអង្គុញចោលឈូង?

ខ៖ ហ្នឹងឯង!

ក៖ លាក់កន្សែងទាញព្រាត់?

ខ៖ ហ្នឹងឯងបទចេះតើ!

ក៖ ចឹងពូចេះច្រើនពូណេះ?

ខ៖ ចេះច្រើនបទអីទៅ។

ក៖ ហើយចុះសព្វថ្ងៃពូគិតថាអើពូទៅលេងភ្លេងអោយគេពូទៅលេងដល់ណាទៅពូ?

ខ៖ លេងដល់បាល្ល័ងកំពង់ធំណោះ។

ក៖ បល្ល័ងកំពង់ធំហោសពូ?

ខ៖ ហ្នឹងឯង!

ក៖ ចុះពូទៅលេងមួយយប់បានប៉ុន្មានទៅពូ?

ខ៖ បានសាមសិបសែសិប។

ក៖ សាមសែសិបរៀលហោសអាហ្នឹងមួយយប់រឺក៏..?

ខ៖ សាមសែសិបម៉ឺន។

ក៖ សាមសែសិបម៉ឺន?

ខ៖ បាទ!

ក៖ អាហ្នឹងចែកគ្នាពីរនាក់រឺក៏ម្នាក់ឯង?

ខ៖ ពីរនាក់។

ក៖ អូ៎!

ខ៖ ដូរពោងគ្នាហ្នឹងយកចែកគ្នា។

កៈ គេហៅពូទៅលេងភ្លេងការពូទៅហាសណោះពូណោះ?

ខៈ ហ្នឹងហើយទៅ។

កៈ អ៊ូ!

ខៈ ជិះទៅថ្ងៃមុនជិះវង្វេងដល់បល្ល័ងមានការពីររោងនេះអានេះលឺមេក្រូឈ្លៀតចូលអារោងផ្សេងច្រឡំ។

កៈ រួចម៉េចទៅពូចឹង?

ខៈ ទៅអង្គុយទៅអង្គុយលេងដូចក្មួយឯងអង្គុយមេក្រូគេផ្សេងការពីរកន្លែងភ្លេងគេណោះលេង។

កៈ ប៉ុន្តែគេអោយលុយយើងតើហីពូហេស?

ខៈ ទេអារឿងគេផ្សេងគេយើងយករោងណោះតើ!

កៈ អ៊ូ!

ខៈ គេអោយយើង។

កៈ បាទពូបាទ!

ខៈ ប៉ុនយើងមានថាយើងយកមួយរោងចែកគ្នាហាសដូចថាមួយរោងយើងចែកគ្នាមួយរោងម្នាក់ៗ។

កៈ អ៊ូចឹងណោះពូណោះ?

ខៈ អើចែកគ្នា។

កៈ អ៊ូ!

ខៈ ហ្នឹងហើយ!

កៈ ប៉ុន្តែពូចឹងមានន័យថាពូរាល់ថ្ងៃពូមានដែរទៅជួយលក់នុំលក់អីប្រពន្ធពូអត់?

ខ៖ អត់ទេនៅផ្ទះតើចាំតែចៅ។

ក៖ អ៊ុំនៅមើលតែចៅណោះពូណោះអ៊ុំ?

ខ៖ អត់ដែរចោលចៅ។

ក៖ អ៊ុំចុះពូគិតថាពូរស់នៅហ្នឹងយូរនៅពូ?

ខ៖ អើពូនៅហ្នឹងរាប់ឆ្នាំទៅហើយ!

ក៖ អ៊ុំរាប់ឆ្នាំហើយណោះពូ?

ខ៖ មិនដែរដើរមានតែពេលរវល់បានពូទៅ។

ក៖ អ៊ុំ!

ខ៖ ពេលហៅលេងភ្លេងគេតេទៅ

ក៖ បាទពូបាទ!

ខ៖ ជិះម៉ូតូទៅ។

ក៖ អ៊ុំហើយចុះពូគិតថាដូចជាចឹងចៅរបស់ពូនៅក្មេងនៅឡើយទេណោះពូណោះប៉ុន្តែកូនរបស់ពូចេះតែផ្តល់អោយអោយតេកតក់ៗអោយមកច្រើនតិចច្រើនៗអោយពូមើលចៅមើលអីកូនអីហាសណោះពូណោះ?

ខ៖ អើគិតដែរហ្នឹងក្មេងប្រាំពីរថ្ងៃគ្នានៅខ្ពស់ដូចបារាំងវាធំសដូចគ្នា។

ក៖ បាទពូបាទហើយចុះពូគិតថាចឹងសំរាប់ពូ ពូសព្វថ្ងៃពូទៅលេងភ្លេងរកត្រី?

ខ៖ ហ្នឹង!

ក៖ ហើយប្រពន្ធពូនៅលក់ដូរ?

ខ៖ លក់ដូរ។

ក៖ អ៊ុំចុះ..?

ខ៖ ពេលទំនេរទៅជួយធ្វើនេះធ្វើនោះ។

ក៖ ហើយចុះអើបងប្អូនពូនៅណាទៅពូ?

ខ៖ នៅនេះតើនៅអាអូននៅនេះនៅកើតមួយ។

ក៖ អូ៎ដែរ..?

ខ៖ បីនាក់។

ក៖ ដែរទៅលេងអីជាមួយគាត់អត់?

ខ៖ ដែរទៅ។

ក៖ ធ្វើការអីជាមួយគាត់អត់?

ខ៖ ទៅមកៗពេលរវល់អីវាហៅ។

ក៖ អូ៎!

ខ៖ ជួយបងជួយប្អូន។

ក៖ ហើយគាត់អោយលុយតាមហ្នឹងហាសណោះ?

ខ៖ បើបងប្អូនមិនយកទេជួយធ្វើផ្ទះអីអោយ។

ក៖ បាទពូបាទ!

ខ៖ ជួយបងប្អូន។

ក៖ អូ៎ចឹងមានន័យថាពូទៅជួយធ្វើផ្ទះធ្វើអីអោយបងប្អូនអីចឹងទៅ?

ខ៖ ហ្នឹងហើយដូចថាគេអ្នកខ្លះគេអោយលុយចឹង។

ក៖ បាទ!

ខ៖ ជួយលើកគេចឹង។

កៈ បាទពូបាទ!

ខៈ បើបងប្អូនយើងគេអោយទេបានយើងគិតហាស!

កៈ បាទពូ!

ខៈ ថ្លៃប្រេងទៅ។

កៈ អ៎ូ!

ខៈ បាទ!

កៈ ហើយចុះពូគិតថាចឹងជីវភាពពូធម្មតាៗទេ?

ខៈ ធម្មតាៗ។

កៈ ហើយចុះប្រពន្ធពូឈ្មោះអីគេពូ?

ខៈ ភូមអូន។

កៈ ភូមអូន?

ខៈ បាទ!

កៈ ប៉ុន្តែអើគាត់អាយុប៉ុន្មានហើយពូ?

ខៈ អាយុ..។

កៈ គាត់អាយុប៉ុន្មានហើយពូឥឡូវ?

ខៈ បងពូមួយឆ្នាំហោស!

កៈ បងពូមួយឆ្នាំហោស?

ខៈ បាទ!

កៈ អ៎ូហាយកាលណុងពូការការនៅណាពូ?

ខ៖ ការនៅចាំតិចការតាំងពី។

ក៖ ប៉ុន្តែពូការការនៅក្នុងភូមិហ្នឹងតើហីពូហី?

ខ៖ ហ្នឹងហើយការនេះប៉ុនទេប៉ៃត្រពីរកៅអ៊ូការហើយកៅសិបកៅបី។

ក៖ ឆ្នាំកៅបីហោសបងហោស?

ខ៖ អើកៅបី។

ក៖ ចុះពូ…?

ខ៖ រួចយូនវាចេញទៅស្រុកហាស!

ក៖ ប៉ុន្តែពូធ្លាប់ឃើញមីងមុនអត់ពីមុនអត់?

ខ៖ ថាម៉េច?

ក៖ ពូធ្លាប់ឃើញមីងពីមុនអត់?

ខ៖ ឃើញអីមិនចង់យកហើយ!

ក៖ អត់ចង់យកហោសប៉ុន្តែឪពុកម្តាយម៉េច?

ខ៖ គេនៅកំពង់ធំហោសអ្នកទៅធ្វើការអីណុង។

ក៖ ប៉ុន្តែឪពុកម្តាយពូបង្ខំអោយយកហោស?

ខ៖ យកអ្នកបងប្អូន។

ក៖ អ៊ូបាទពូបាទ!

ខ៖ ហ្នឹងហើយបងប្អូន។

ក៖ បាទពូហើយចុះបើសិនជាចង់អោយពូផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗរបស់ពូហាសពូមានពាក្យពេចន៍អីដែរចង់ផ្តែផ្តាំទៅពួកគាត់ដើម្បីអោយពួកគាត់ខំប្រឹងរៀនទេពូជាពិសេសចៅរបស់ពូហាស?

ខ៖ អើ..!

ក៖ ពូធ្លាប់ផ្ដែផ្ដាំទៅពួកគាត់អត់?

ខ៖ អើផ្ដាំ។

ក៖ ប៉ុន្ដែ..?

ខ៖ គេបង្ហោះមកសម្លាសហ្នឹងបង្ហោះ។

ក៖ បាទពូបាទចុះពូធ្លាប់អោយពួកគាត់អើធ្លាប់អោយពួកគាត់ជៀសវៀងពីអំពើដៃរអត់ល្អនៅក្នុងសង្គមទេពូ?

ខ៖ ទេហាមពីយើងកុំប្រើអំពើហឹង្សា។

ក៖ ចឹងហេសពូហេស?

ខ៖ បាទ!

ក៖ អូ៎បាទពូ!

ខ៖ យើងហូបស្រវឹងដាក់មួយកំប៉ុងដេកទៅ។

ក៖ បាទត្រូវពូ?

ខ៖ ណាស់ក្មួយណាស់។

ក៖ បាទពូបាទ!

ខ៖ ដូចក្មួយឯងឥឡូវនេះ។

ក៖ អូ៎!

ខ៖ មែនយើងប្រើអំពើហឹង្សាទេ។

ក៖ បាទពូបាទ!

ខ៖ បើថាយើងស្រវឹងដេកទេមានអ្នកលួងចែកបើមានអ្នករាំក៏រាំអីទៅអី។

ក៖ បាទពូ!

ខ៖ អើ..!

ក៖ ចឹងពូមានអីដែរចង់ផ្ដែផ្ដាំផ្សេងទៀតអត់ពូអស់ហើយណោះពូណោះ?

ខ៖ អើ!

ក៖ ចឹងប្រហែលចុងក្រោយខ្ញុំអរគុណច្រើនពូដែរបានអោយខ្ញុំពិភាក្សាជាមួយពូទាក់ទងពីប្រវត្តិរបស់ពូបាទអរគុណច្រើនពូ៕